**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**

លេខ : ០៧៥/០១៩/២០០៣

ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ២០០៣

**សេចក្តីសម្រេច**

លេខ : ០៥៨/០០៩/២០០៣ កបធ.ច

ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ២០០៣

# ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៧/០៦ ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ១៩៩៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៧ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ២០០២ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញសេចក្តីសម្រេចលេខ ០៤៦/០០១/២០០២ កបធ.ច ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ២០០២ របស់ក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញលិខិតលេខ ៤២៧ រស ចុះថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ២០០៣ របស់សម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** ប្រធានរដ្ឋសភាបញ្ជូនលិខិតលោក **គល់ បញ្ញា** នាយកប្រតិបត្តិរបស់គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និង យុត្តិធម៌នៅកម្ពុជា ( COMFREL ) មកក្រុមប្រឹក្សាធម្មនុញ្ញសុំឱ្យធ្វើការបកស្រាយមាត្រា ១២៤ ថ្មី វាក្យខ័ណ្ឌទី១ នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំង-តំណាងរាស្ត្រ តាមពាក្យបណ្តឹង លេខ ២៨៧/គ.ប.ស.យ ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ២០០៣ ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញទទួលបាននៅថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ២០០៣

**ក្រោយពីបានស្តាប់របាយការណ៍សមាជិករាយការណ៍**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា តាមមាត្រា ១៤១ ថ្មី នៃរដ្ឋធម្មនុញ្ញ និង មាត្រា ១៨ នៃព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ពាក្យបណ្តឹងរបស់សម្តេចក្រុមព្រះប្រធានរដ្ឋសភា ក្រុមប្រឹក្សាធម្មនុញ្ញអាចទទួលយកមកពិនិត្យពិភាក្សាបាន
- យល់ឃើញថា មាត្រា ៧៦ វាក្យខ័ណ្ឌទី ៥ នៃរដ្ឋធម្មនុញ្ញ បានបញ្ញត្តិឱ្យច្បាប់បោះឆ្នោតកំណត់អំពី " អង្គការរៀបចំការបោះឆ្នោត បែបបទ និង ការប្រព្រឹត្តទៅនៃការបោះឆ្នោត "
- យល់ឃើញថា តាមការបញ្ជាក់របស់ក្រសួងមហាផ្ទៃ ដែលជាអ្នកតាក់តែងសេចក្តីព្រាងដើមនៃច្បាប់បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ គំនិតគឺឱ្យ គ.ជ.ប ជាអ្នកធ្វើការពិន័យ
- យល់ឃើញថា តាមកំណត់ហេតុនៃការពិភាក្សានៅរដ្ឋសភានាឆ្នាំ២០០២ និង ឆ្នាំ១៩៩៧ ពុំមានយោបល់សុំកែប្រែគំនិតដើមរបស់សេចក្តីព្រាងមាត្រា ១២៤ ថ្មី និង មាត្រា ១២៤ ចាស់ លើចំណុចខាងលើនេះទេ
- យល់ឃើញថា មាត្រា ១២៤ ថ្មី វាក្យខ័ណ្ឌទី១ នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្របានចែងថា " ត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតលុបបេក្ខភាពរបស់សាមីខ្លួន ឬ លុបបេក្ខភាពឈរឈ្មោះរបស់គណបក្សនយោបាយ ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឬ/ និង ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីប្រាំលាន ( ៥.០០០.០០០ ) រៀល ទៅម្ភៃប្រាំលាន ( ២៥.០០០.០០០ ) រៀល ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ... " ។ ក្នុងឃ្លានេះ យោងតាមទទ្ធិករណ៍ខាងលើការពិន័យជាប្រាក់ ក៏ស្ថិតនៅក្នុងសមត្ថកិច្ចរបស់ គ.ជ.ប ដែរ ។

## សម្រេច

**មាត្រា ១** : មាត្រា ១២៤ ថ្មី វាក្យខ័ណ្ឌទី១ នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ត្រូវបកស្រាយដូចមានក្នុងមូលបទខាងលើ ។

**មាត្រា ២** : សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ២០០៣ នាសម័យប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ២០០៣

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

**ហត្ថលេខា និង ត្រា**

**ប៊ិន ឈិន**